ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៦.....សហវ...៣ដ

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ - ឆ្នាំ២០០៦

លិខិតចូល
ថ្ងៃទី ០៥ ខែ ៥ ឆ្នាំ2006

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៦

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទមេត្តាជ្រាបថា : ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៦ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៦ ។

<u>ពន្ធនេះត្រូវបានលើកលែងមិនប្រមូលចំពោះ :</u>

- រថយន្តសង្គ្រោះបន្ទាន់ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះរបស់ស្ថានទូត កុងស៊ុល អង្គការ ឬបុគ្គលដែលមានលក្ខន្តិកៈជាអ្នកការទូត ឬកុងស៊ុល ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៦ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៥ សំរាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ រួចហើយ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបញ្ជាក់ពីការបានបង់ពន្ធឆ្នាំ២០០៥ ទេនោះ ត្រូវបង់ពន្ធសំរាប់ឆ្នាំ២០០៥ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៦។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនិមួយៗ ត្រូវបានទទួលប័ណ្ណបង់ពន្ធមួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនិមួយៗ និង បង្កាន់ដៃបង់ពន្ធមួយសន្លឹកទៀត ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៦ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៦ តទៅ ។

ការត្រួតពិនិត្យនេះ និង ត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយ ក្នុងភូមិ ឃុំ សង្កាត់ ... និង ទីចំណតនានា ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាប្រញាប់ប្រញាល់រួសរាន់អញ្ជើញទៅបង់ពន្ធនេះអោយបានមុនថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៦ កុំបីខាន ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់